លេខ ៥៨ ចេញផ្សាយថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៦

# ព្រឹត្តិបត្រព័ត៌មាន

## ប្រចាំខែមេសា ឆ្នាំ២០២៦

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## មាតិកា


- សិក្ខាសាលាលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច ស្តីពី "ការខកខានក្នុងការអនុលោមតាមអនុសាសន៍និងលទ្ធផលជាក់ស្តែងរបស់ FATF ដែលបណ្តាលឱ្យប្រទេសមួយធ្លាក់ចូលក្នុងបញ្ជីប្រផេះ/ខ្មៅ"...... ទំព័រទី ១
- សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើ "សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងវិស័យបរធនបាលកិច្ច"..ទំព័រទី ២
- កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ និងទិសដៅការងារបន្ត" របស់ ន.ប.ធ...... ទំព័រទី ២
- សិក្ខាសាលាស្តីពី "យន្តការ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច"...... ទំព័រទី ២
- ពិធីសូត្រមន្តចម្រើនព្រះបរិត្ត ប្រោះព្រំសិរីសួស្តីចូលឆ្នាំថ្មីប្រពៃណីខ្មែរ...... ទំព័រទី ៣
- ពិធី "ប្រកាសដាក់ឱ្យអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំហានទី៤ ឆ្នាំ២០២៦-២០៣០ និងប្រកាសដាក់ឱ្យអនុវត្តគម្រោងអ៊ីនត្រាណិត **កសហវ** ជំហានទី២ ជាផ្លូវការ"...... ទំព័រទី ៣
- កិច្ចប្រជុំតាមប្រព័ន្ធអនឡាញរបស់ថ្នាក់ដឹកនាំ **ន.ប.ធ.** ជាមួយតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)...... ទំព័រទី ៤
- ទិន្នន័យប្រតិបត្តិការក្នុងវិស័យបរធនបាលកិច្ចសម្រាប់ត្រីមាសទី១ ឆ្នាំ២០២៦...... ទំព័រទី ៤
- ពិធីសំណេះសំណាលនិវត្តជនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**)...... ទំព័រទី ៤
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ឆ្នាំ២០២៥-២០៣០"...... ទំព័រទី ៥
- កិច្ចប្រជុំពិនិត្យនិងពិភាក្សាលើ "សេចក្តីព្រាងផែនការយុទ្ធសាស្ត្រគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ២០២៦-២០៣០"...... ទំព័រទី ៥
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP"...... ទំព័រទី ៦
- កិច្ចប្រជុំសមាសភាពក្រុមការងារទទួលបន្ទុករៀបចំយុទ្ធសាស្ត្រជាតិនិងត្រៀម និងទទួលការវាយតម្លៃអញ្ញមញ្ញ ឆ្នាំ២០២៨-២០២៩ ស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ...... ទំព័រទី ៦
- កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ **ន.ប.ធ.** ជាមួយ The STEP HK Chapter Chairman...... ទំព័រទី ៦
- កម្មវិធី "ទិវាធានារ៉ាប់រងកម្ពុជា ២០២៦"...... ទំព័រទី ៧
- វេទិកាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP"...... ទំព័រទី ៧


## សិក្ខាសាលាលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច ស្តីពី "ការខកខានក្នុងការអនុលោមតាមអនុសាសន៍និងលទ្ធផលជាក់ស្តែងរបស់ FATF ដែលបណ្តាលឱ្យប្រទេសមួយធ្លាក់ចូលក្នុងបញ្ជីប្រផេះ/ខ្មៅ"

នារសៀលថ្ងៃពុធ ១៤កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយ **លោក ផែម លាបហេង អនុប្រធាននាយកដ្ឋាន**



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

**កិច្ចការគតិយុត្តនិងអធិការកិច្ចនៃ ន.ប.ធ.** និងក្រុមការងារ បានចូលរួមក្នុងសិក្ខាសាលាលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច ស្តីពី "ការខកខានក្នុងការអនុលោមតាមអនុសាសន៍និងលទ្ធផលជាក់ស្តែងរបស់ FATF ដែលបណ្តាលឱ្យប្រទេសមួយធ្លាក់ចូលក្នុងបញ្ជីប្រផេះ/ខ្មៅ" របស់ក្រុមការងារហិរញ្ញវត្ថុសហការរៀបចំឡើងដោយ **ន.ប.ធ.** និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ។ សិក្ខាសាលានេះ មានការចូលរួមពីបុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច ដែលមានសិក្ខាកាមសរុបប្រមាណ ៨០ រូប។



**រូបភាព៖** សិក្ខាសាលាលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច ស្តីពី "ការខកខានក្នុងការអនុលោមតាមអនុសាសន៍និងលទ្ធផលជាក់ស្តែងរបស់ FATF ដែលបណ្តាលឱ្យប្រទេសមួយធ្លាក់ចូលក្នុងបញ្ជីប្រផេះ/ខ្មៅ"។

## សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើ "សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងវិស័យបរធនបាលកិច្ច"

នាព្រឹកថ្ងៃព្រហស្បតិ៍ ១៥កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើ "សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** តាមរយៈប្រព័ន្ធអនឡាញ Zoom។ សេចក្តីព្រាងគោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណង ជំរុញនិងពង្រឹងការអនុវត្តកាតព្វកិច្ចរបស់បរធនបាល និងប្រតិបត្តិករបរធនបាល ក្នុងការយកចិត្តទុកដាក់ស្គាល់អតិថិជន និងប្រភពបរធនរបស់អតិថិជន មុនពេលស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ច និងក្នុងអំឡុងពេលបរធនបាលកិច្ចមានសុពលភាព ដើម្បីធានាអនុលោមភាពច្បាប់ និងបទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងអនុលោមតាមស្តង់ដាអន្តរជាតិផងដែរ។

សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈនេះ ក៏មានការចូលរួមពីតំណាងអគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.**, តំណាងនិយ័តករក្រោមឱវាទ **អ.ស.ហ.**, តំណាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា, ក្រុមហ៊ុនបរធនបាល, ធនាគារពាណិជ្ជដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាពឬសេវារក្សាទុក, បរធនបាលរូបវន្តបុគ្គលឯករាជ្យ, ក្រុមហ៊ុនវាយតម្លៃ និងក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងស្ថាប័ននិងបុគ្គលពាក់ព័ន្ធ។



**រូបភាព៖** សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើ "សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងវិស័យបរធនបាលកិច្ច"។

## កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ និងទិសដៅការងារបន្ត" របស់ ន.ប.ធ.

នាសៀលថ្ងៃព្រហស្បតិ៍ ១៥កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.** ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

នៅក្នុងកិច្ចប្រជុំនេះ មានការធ្វើបទបង្ហាញពីគ្រប់នាយកដ្ឋានចំណុះនៃ **ន.ប.ធ.** ដោយបានបង្ហាញពីសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ និងទិសដៅការងារបន្ត ព្រមទាំងមានការពិភាក្សាយ៉ាងផុសផុលក្នុងកម្រិតមន្ត្រី និងថ្នាក់ដឹកនាំរបស់ **ន.ប.ធ.** លើបញ្ហាប្រឈម និងដំណោះស្រាយដែលបានអនុវត្តកន្លងមក និងលើកឡើងនូវវិធីសាស្រ្ត ដើម្បីត្រៀមខ្លួនក្នុងការអនុវត្តការងារនៅត្រីមាសបន្ទាប់ឱ្យកាន់តែល្អប្រសើរថែមទៀត។




រូបភាព៖ កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.**។

## សិក្ខាសាលាស្តីពី "យន្តការ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច"

នាព្រឹកថ្ងៃសុក្រ ១រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "យន្តការ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និង **បណ្ឌិត ឈីវ ថេត សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា** នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការ និងប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ**ន.ប.ធ.**និងមន្ត្រីជំនាញ,សាស្ត្រាចារ្យនិងនិស្សិតនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។




រូបភាព៖ សិក្ខាសាលាស្តីពី "យន្តការ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច"។

## ពិធីសូត្រមន្តចម្រើនព្រះបរិត្ត ប្រោះព្រំសិរីសួស្តីចូលឆ្នាំថ្មីប្រពៃណីខ្មែរ

នាព្រឹកថ្ងៃចន្ទ ៤រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសហការីបានអញ្ជើញចូលរួមក្នុងពិធីសូត្រមន្តចម្រើនព្រះបរិត្ត ប្រោះព្រំសិរីសួស្តីចូលឆ្នាំថ្មីប្រពៃណីខ្មែរ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

ពិធីនេះមានការអញ្ជើញចូលរួមជាអធិបតីរបស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ.** និង **ឯកឧត្តមបណ្ឌិត ឌី តាយី រដ្ឋលេខាធិការ កសហវ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តមបណ្ឌិតរដ្ឋលេខាធិការទទួលបន្ទុកជាអគ្គនាយក, ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក, ឯកឧត្តមអគ្គនាយក និងឯកឧត្តម លោកជំទាវ ជាសមាជិក-សមាជិកាក្រុមប្រឹក្សានៃ **អ.ស.ហ.** ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.**។




រូបភាព៖ ពិធីសូត្រមន្តចម្រើនព្រះបរិត្ត ប្រោះព្រំសិរីសួស្តីចូលឆ្នាំថ្មីប្រពៃណីខ្មែរ។

## ពិធី "ប្រកាសដាក់ឱ្យអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំហានទី៤ ឆ្នាំ២០២៦-២០៣០ និងប្រកាសដាក់ឱ្យអនុវត្តគម្រោងអ៊ីនត្រាណិត កសហវ ជំហានទី២ ជាផ្លូវការ"

នាព្រឹកថ្ងៃអង្គារ ៥រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៦ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **លោក-**

**ចេស ចាន់ដេត ប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យានៃនាយកដ្ឋានកិច្ចការទូទៅ** និងសហការី បានអញ្ជើញចូលរួមពិធី "ប្រកាសដាក់ឱ្យអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំហានទី៤ ឆ្នាំ២០២៦-២០៣០ និងប្រកាសដាក់ឱ្យអនុវត្តគម្រោងអ៊ីនត្រាណិត **កសហវ** ជំហានទី២ ជាផ្លូវការ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** (**កសហវ**) និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន និងអង្គភាពក្រោមឱវាទ កសហវ នៅសណ្ឋាគារ សុខា ភ្នំពេញ។



រូបភាព៖ ពិធី "ប្រកាសដាក់ឱ្យអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំហានទី៤ ឆ្នាំ២០២៦-២០៣០ និងប្រកាសដាក់ឱ្យអនុវត្តគម្រោងអ៊ីនត្រាណិត **កសហវ** ជំហានទី២ ជាផ្លូវការ"។

## កិច្ចប្រជុំតាមប្រព័ន្ធអនឡាញរបស់ថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

កាលពីថ្ងៃចន្ទ ៤ រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 បានដឹកនាំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ជាមួយតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF-GDICDM) ដើម្បីពិភាក្សាលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀងកម្ចីឧបត្ថម្ភធន (Subsidiary Loan Agreement – SLA) ថ្មី ដែលត្រូវចុះហត្ថលេខារវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយស្ថាប័នហិរញ្ញវត្ថុដៃគូចំនួន ៥ ថ្មីរបស់គម្រោង ACSEP។



រូបភាព៖ កិច្ចប្រជុំតាមប្រព័ន្ធអនឡាញរបស់ថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

## ទិន្នន័យប្រតិបត្តិការក្នុងវិស័យបរធនបាលកិច្ច សម្រាប់ត្រីមាសទី១ ឆ្នាំ២០២៦

និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) សូមជូននូវទិន្នន័យប្រតិបត្តិការក្នុងវិស័យបរធនបាលកិច្ច សម្រាប់ត្រីមាសទី១ ឆ្នាំ២០២៦ ដល់សាធារណជន។




រូបភាព៖ ទិន្នន័យប្រតិបត្តិការក្នុងវិស័យបរធនបាលកិច្ច សម្រាប់ត្រីមាសទី១ ឆ្នាំ២០២៦។

## ពិធីសំណេះសំណាលនិវត្តជនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)

នាព្រឹកថ្ងៃពុធ ៦រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៦ **ឯកឧត្តម នាង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមពិធីសំណេះសំណាលនិវត្តជនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**កសហវ**) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់

ទំព័រទី៤

**លោកជំទាវ កែវ ចរិយា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានសមាគមសង្គហៈមិត្ត តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំក្រសួងស្ថាប័ន-អង្គភាព និងនិវត្តជន **កសហវ** នៅសាលាជាតិគយ។




រូបភាព៖ ពិធីសំណេះសំណាលនិវត្តជនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)។

## សិក្ខាសាលាផ្សព្វផ្សាយស្ដីពី “យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ឆ្នាំ២០២៥-២០៣០”

នាព្រឹកថ្ងៃចន្ទ ៤កើតខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៦, **លោក យុន វាសនា** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្ដីពី “យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ឆ្នាំ២០២៥-២០៣០” ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ប៊ូ ច័ន្ទសិរី អគ្គនាយកនៃនិយ័តករធានារ៉ាប់រងនៃកម្ពុជា** នៅទីស្ដីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងមានការអញ្ជើញចូលរួមពីតំណាងនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** ព្រមទាំងភាគីពាក់ព័ន្ធក្នុងវិស័យធានារ៉ាប់រង។




រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយស្ដីពី “យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ឆ្នាំ២០២៥-២០៣០”។

## កិច្ចប្រជុំពិនិត្យនិងពិភាក្សាលើ "សេចក្ដីព្រាងផែនការយុទ្ធសាស្ត្រគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ២០២៦-២០៣០"

នាព្រឹកថ្ងៃចន្ទ ៤កើតខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៦, **លោក យុន វាសនា** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើ "សេចក្ដីព្រាងផែនការយុទ្ធសាស្ត្រគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ២០២៦-២០៣០" ក្រោមការសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ព្រមទាំងមានការចូលរួមពីឯកឧត្តម លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ និងតំណាងអង្គភាពក្រោមឱវាទ **អ.ស.ហ.**។




រូបភាព៖ កិច្ចប្រជុំពិនិត្យនិងពិភាក្សាលើ "សេចក្ដីព្រាងផែនការយុទ្ធសាស្ត្រគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ២០២៦-២០៣០"។

## សិក្ខាសាលាស្ដីពី “ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP”

ចាប់ពីថ្ងៃចន្ទ ៤កើត ដល់ថ្ងៃពុធ ៦កើត ខែពិសាខ ឆ្នាំមមី សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២០ ដល់ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្ដីពី “ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP” ក្រោមការដឹកនាំរបស់ **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្ដុះបណ្ដាល និងសហប្រតិបត្តិការនៃ ន.ប.ធ.** និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1 តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយ អំពីសាវតារ និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេស គោលនយោបាយឥណទាន បែបបទ និងនីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះ និងគាំទ្រដល់សហគមន៍កសិកម្ម និងកសិធុរកិច្ច ដល់សមាជិកនៃសហគមន៍កសិកម្មរីកចម្រើនភូមិថ្មី សហគមន៍កសិកម្មកំពង់ប្រាសាទ សហគមន៍កសិកម្មបន្លែបៃតង តំណាងសហគមន៍កសិកម្មបន្លែចម្រុះឃុំព្រែកអំបិល សហគមន៍កសិកម្មបន្លែសុវត្ថិភាពចម្រុះឃុំកោះខែល ដែលស្ថិតនៅស្រុកមុខកំពូល ស្រុកកោះធំ និងស្រុកស្អាង ខេត្តកណ្ដាល ដែលមានបំណងស្វែងរកហិរញ្ញប្បទាន ដើម្បីគាំទ្រ និងពង្រីកអាជីវកម្មរបស់ខ្លួន។

សិក្ខាសាលានេះ មានការចូលរួមដោយ សមាជិកសហគមន៍កសិកម្ម និងកសិធុរកិច្ចខាងលើ, មន្ត្រី និងទីប្រឹក្សារបស់គម្រោង ACSEP-PIU1, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកណ្ដាល, និងក្រុមការងារគម្រោងមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារស្ថាបនា (Sathapana Bank)។



**រូបភាព៖** សិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP"។

## កិច្ចប្រជុំសមាសភាពក្រុមការងារទទួលបន្ទុករៀបចំយុទ្ធសាស្ត្រជាតិនិងត្រៀម និងទទួលការវាយតម្លៃអញ្ញមញ្ញ ឆ្នាំ២០២៨-២០២៩ ស្ដីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

នារសៀលថ្ងៃពុធ ៦កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៦ វេលាម៉ោង ១៤:00 នាទី នៅធនាគារជាតិនៃកម្ពុជា (**អគារសែនសុខ**) ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច**នៃ **ន.ប.ធ.** អមដោយមន្ត្រីជំនាញបានចូលរួមកិច្ចប្រជុំសមាសភាពក្រុមការងារទទួលបន្ទុករៀបចំយុទ្ធសាស្ត្រជាតិនិងត្រៀម និងទទួលការវាយតម្លៃអញ្ញមញ្ញ ឆ្នាំ២០២៨-២០២៩ ស្ដីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដែលបានប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ហេង ប៊ុមករា ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា** ដែលបានអញ្ជើញជាសហប្រធានជាមួយ **ឯកឧត្តម ហាក់ សុខហេង** អនុរដ្ឋលេខាធិការដ្ឋានក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងជាអនុប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (**គ.ស.ហ.**)។ កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីតំណាងក្រសួង-ស្ថាប័នសមាជិកពាក់ព័ន្ធ។



**រូបភាព៖** កិច្ចប្រជុំសមាសភាពក្រុមការងារទទួលបន្ទុករៀបចំយុទ្ធសាស្ត្រជាតិនិងត្រៀម និងទទួលការវាយតម្លៃអញ្ញមញ្ញ ឆ្នាំ២០២៨-២០២៩ ស្ដីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

## កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយ The STEP HK Chapter Chairman

នាព្រឹកថ្ងៃសុក្រ ៨កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៦ **ឯកឧត្តម ណឺ សារ៉ាកល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** រួមជាមួយ **លោក យុន វាសនា** អគ្គនាយករងនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចពិភាក្សាការងារជាមួយ **លោក** Mr. Paul Knox The STEP HK Chapter Chairman អំពីទីផ្សារបរធនបាលកិច្ច និងអ្វីដែល អាចផ្ដល់សម្រាប់ការគាំទ្រដល់ការអភិវឌ្ឍន៍ ការគ្រប់គ្រងវិស័យបរធនបាលកិច្ច នៅព្រះរាជាណាចក្រកម្ពុជា។



រូបភាព៖ កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ **ន.ប.ធ.** ជាមួយ The STEP HK Chapter Chairman។

## កម្មវិធី "ទិវាធានារ៉ាប់រងកម្ពុជា ២០២៦"

នាព្រឹកថ្ងៃសៅរ៍ ៩កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៦៩ត្រូវនឹងថ្ងៃទី២៥ខែមេសាឆ្នាំ២០២៦ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមកម្មវិធី "ទិវាធានារ៉ាប់រងកម្ពុជា ២០២៦" ដែលរៀបចំដោយនិយ័តករធានារ៉ាប់រងកម្ពុជា ចាប់ពីថ្ងៃទី២៥-២៦ ខែមេសា ឆ្នាំ២០២៦ នៅខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម វង្ស វិសិទ្ធ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (**អ.ស.ហ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.**។



រូបភាព៖ កម្មវិធី "ទិវាធានារ៉ាប់រងកម្ពុជា ២០២៦"។

## វេទិកាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP"

ចាប់ពីថ្ងៃចន្ទ ១១កើត ដល់ថ្ងៃពុធ ១៣កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៧ ដល់ថ្ងៃទី២៩ខែមេសា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែប្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំវេទិកាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP" ក្រោមការដឹកនាំរបស់ **លោក ហេង សំអុល ប្រធានការិយាល័យសហប្រតិបត្តិការនៃនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាមន្ត្រីលទ្ធកម្មនៃគម្រោង** ACSEP-PIU1។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសារៈតារ និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេស គោលនយោបាយឥណទាន បែបបទ និងនីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះ និងគាំទ្រដល់សហគមន៍កសិកម្ម និងកសិធុរកិច្ច ដល់សមាជិកនៃសហគមន៍កសិកម្មចំនួន ៥ រួមមាន៖ សហគមន៍កសិកម្មឧត្តមសុរិយា, សហគមន៍កសិកម្មទំនើបបន្លែផ្ទះសំណាញ់ត្រាំកក់, សហគមន៍កសិកម្មនោមសាមគ្គី, សហគមន៍កសិកម្មសំភ្លីអង្គរវង្សី និងសហគមន៍កសិកម្មបក្សីរីករាយ ខេត្តតាកែវ ដែលមានបំណងស្វែងរកហិរញ្ញប្បទាន ដើម្បីគាំទ្រ និងពង្រីកអាជីវកម្ម ក៏ដូចជាមុខរបររបស់ខ្លួន។ វេទិកានេះ មានការចូលរួមដោយតំណាងសមាជិក-សមាជិកាសហគមន៍កសិកម្ម, មន្ត្រី និងទីប្រឹក្សារបស់គម្រោង ACSEP-PIU1, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ, មេឃុំ-ក្រុមប្រឹក្សាឃុំ និងមេភូមិ មន្ត្រីកសិកម្មឃុំ និងក្រុមការងារគម្រោងមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារស្ថាបនា (Sathapana Bank)។



រូបភាព៖ វេទិកាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP"។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888